សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ១៥ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# ដើម្បីកាត់បន្ថយការរីករាលដាល សាលាក្រុង Chelsea និង Revere ប្រកាសយក "The Inn" ធ្វើជាកន្លែងព្យាបាលពីជំងឺ និងដាក់មនុស្សដោយឡែកជាបណ្តោះអាសន្ន

*ដោយសហការណ៍ជាមួយ MGH ដើម្បីរៀបចំ និងផ្តល់សេវាកម្មពេទ្យដល់អ្នកជំងឺចំនួន ១៥០នាក់*

Revere ថ្ងៃទី ១៥ មេសា ២០២០- ដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19 សាលាក្រុង Revere ដឹកនាំដោយលោកអភិបាល Brain Arrigo និងអ្នកគ្រប់គ្រងក្រុង Chelsea លោក Tom Ambrosino បានប្រកាសយកទីតាំងមួយដែលគ្មានមនុស្សនៅ មកធ្វើកន្លែងសម្រាប់ឲ្យអ្នកជំងឺសម្រាកព្យាបាលបែបដាច់ដោយឡែក ដោយមិនការប្រើប្រាស់ឧបករណ៍ ឬថ្នាំពេទ្យ។ នេះក៏ជាកន្លែងសុវត្ថិភាពមួយសម្រាប់អ្នកដែល តម្រូវឲ្យរស់នៅដាច់ផងឡែកផងដែរ។

The Quality Inn ដែលមានទីតាំងក្នុងក្រុង Revere បានធ្វើកិច្ចព្រមព្រៀងឲ្យរដ្ឋាភិបាលប្រចាំ Revere និង Chelsea ប្រើប្រាស់អគារទាំងមូល ធ្វើជាកន្លែងសម្រាកព្យាបាល និងដាក់មនុស្សនៅដាច់ដោយឡែក ក្នុងរយៈពេល ៦០ ថ្ងៃ។ លក្ខខណ្ឌសម្រាប់អ្នកដែលត្រូវស្នាក់នៅទីនេះ គឺសម្រាប់ដែលរស់នៅក្នុងតំបន់មានមនុស្សច្រើន ឬកន្លែងដែលមានហានិភ័យនៃការឆ្លងខ្ពស់។

HealthCare បានបង្កើនក្រុមផ្តល់សេវាថៃទាំសុខភាពតាមបន្ទប់ ដើម្បីកាត់បន្ថយការធ្វើដំណើរទៅមករបស់គ្រូពេទ្យពីមន្ទីរពេទ្យ មកកន្លែងសម្រាកព្យាបាលនេះ។ ក្នុងនោះ ក្រុមហ៊ុនភាគីទីបី នឹងទទួលខុសត្រូវ ក្នុងត្រួតពិនិត្យរាល់ប្រតិបត្តិការដែលមិនទាក់ទងនឹងក្បួនវេជ្ជសាស្រ្ត រួមទាំងផ្នែកសន្តិសុខសុវត្ថិភាព។

"យើងដឹងថាវិធីល្អបំផុតដើម្បីការពារប្រជាជនទាំងអស់ពីការឆ្លងជំងឺ គឺជៀសវាងការប៉ះពាល់គ្នា។ យើងនឹងផ្តល់ជូននូវកន្លែងសុវត្ថិភាពសម្រាប់ការរស់នៅដាច់ដោយឡែកនេះ ទៅកាន់អ្នកដែលមានតម្រូវការ ដើម្បីកាត់បន្ថយល្បឿននៃការរីករាលដាលបន្តទៀត" ។ លោកអភិបាល Arrigo និយាយ។

"កិច្ចសហការរវាងក្នុងក្រុងទាំង ២ នេះ គឺធ្វើឡើងយ៉ាងល្អិនល្អន់ ហើយយើងសង្ឃឹមថាយើងពិតជាអាចកាត់បន្ថយការរាតត្បាតជាសកលនេះ ក្នុងដំណាក់កាលដែលវាកំពុងរាលដាលក្នុង Chelsea ក៏ដូចជា Revere"។ លោក Ambrosino និយាយ។ "កន្លែងស្នាក់នៅបណ្តោះអាសន្ននេះ នឹងធានាថា សុខភាពរបស់ប្រជាជន ពិសេសអ្នកដែលមានលំនៅក្នុងតំបន់មានមនុស្សច្រើន ត្រូវបានការពារ"។

បុគ្គលដែលអាចរស់នៅក្នុង The Inn បាន ត្រូវលក្ខខណ្ឌដូចជា៖

- ជាអ្នករស់នៅក្នុងក្រុង Revere ឬ Chelsea
- ជាអ្នកមានផ្ទុកមេរោគ COVID-19
- ត្រូវបានគ្រូពេទ្យបញ្ជាក់ថា អាចសម្រាកព្យាបាលដោយមិនត្រូវប្រើប្រាស់ថ្នាំបាន
- ជាអ្នករស់នៅក្នុងស្ថានភាព ឬស្ថិតក្នុងដំណាក់កាលដែលតម្រូវឲ្យរស់នៅម្នាក់ឯង ឬដំណាក់កាលរស់នៅដាច់ដោយឡែក។

មន្ត្រីសាធារណៈប្រចាំ Chelsea និង Revere នឹងពិគ្រោះយោបល់ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ ដើម្បីបញ្ជាក់ថាបុគ្គលបែបណា ត្រូវដែលស្របតាមលក្ខខណ្ឌ អាចចូលទៅស្នាក់នៅទីនោះបាន។ The Inn នឹងមិនទទួលយកអ្នកជំងឺ "Walk-In" នោះទេ។

The Inn នឹងផ្តល់ជូនឲ្យបុគ្គលណា ដែលរស់នៅក្នុងតំបន់មានការរីករាលដាលខ្លាំង នូវទីតាំងដែលមានសន្តិសុខសុវត្ថិភាព និងមានបុគ្គលិកបម្រើពេញលេញតាមក្បួនវេជ្ជសាស្ត្រ។ បន្ទប់ភាគច្រើន អាចឲ្យមនុស្សម្នាក់ស្នាក់នៅ ហើយបន្ទប់មួយចំនួននឹងផ្តល់ឲ្យស្នាក់នៅជាលក្ខណៈគ្រួសារតែម្តង។

៧៥% នៃការចំណាយសម្រាប់ការព្យាបាលក្នុង The Inn នឹងត្រូវបានរ៉ាប់រងដោយ FEMA រួមជាមួយជំនួយបន្ថែមពី MEMA។ ឯការចំណាយដែលនៅសល់ នឹងត្រូវរ៉ាប់រងដោយរដ្ឋាភិបាលរបស់ក្រុង Chelsea និង Revere។ រាល់អ្នកជំងឺ និងបុគ្គលិកទាំងអស់ នឹងទទួលបានសម្ភារៈការពារពីជំងឺដោយ MEMA។ MEMA ក៏នឹងផ្តល់ជូនសេវាដឹកជញ្ជូនម្ហូបអាហារ ៣ ពេលក្នុងមួយថ្ងៃដល់អ្នកជំងឺផងដែរ។ ប៉ូលីសប្រចាំក្រុង Revere និង Chelsea នឹងធ្វើការការពារសុវត្ថិភាពនៅទីនោះរយៈពេល ២៤ ម៉ោង។ ក្រុមពន្លត់អគ្គិភ័យរបស់ Revere និង រថយន្តពន្លត់អគ្គិភ័យ Cataldo នឹងរៀបចំក្រុមសង្គ្រោះបន្ទាន់ ឲ្យប្រចាំការនៅអគារនេះផងដែរ៕

###